ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

**ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**ទទួលជួបឯកឧត្តម LIU GUANGYUAN អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការ**
**សន្តិសុខក្រៅប្រទេស របស់ក្រសួងការបរទេសចិន**
******

កាលពីថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០១៦ វេលាម៉ោង៣:៣០ នាទីរសៀល **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតអោយគណៈប្រតិភូដឹកនាំដោយឯកឧត្តម LIU GUANGYUAN អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសន្តិសុខ ក្រៅប្រទេសរបស់ក្រសួងការបរទេសចិន ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

បន្ទាប់ពីសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅ ចំពោះទស្សនកិច្ចរបស់គណៈប្រតិភូ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការរីករាយពេញចិត្តចំពោះការវិវឌ្ឍន៍ដ៏ល្អប្រសើរ នៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ ដែលត្រូវបានថ្នាក់ដឹកនាំនៃប្រទេសទាំងពីរលើកកំពស់ដល់កំរិត «**ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ**» កាលពីខែធ្នូ ឆ្នាំ២០១០ កន្លងមកនេះ ព្រមទាំងការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសទាំងពីរ ក្នុងឆ្នាំ២០១៦ នេះ ដែលរួមមាន ព្រះរាជទស្សនកិច្ចផ្លូវរដ្ឋរបស់ព្រះករុណា ព្រះមហាក្សត្រកម្ពុជា ទស្សនកិច្ចរបស់អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទស្សនកិច្ចផ្លូវការរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ទស្សនកិច្ចរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ផ្ទាល់ ហើយនិងទស្សនកិច្ចនៅកម្ពុជារបស់ឯកឧត្តម ប្រធានាធិបតី Xi Jing Ping ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការបរទេសចិន WANG YI ចំនួន ០២លើក ឯកឧត្តមរដ្ឋមន្ត្រីពាណិជ្ជកម្ម និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិចិន។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការរីករាយពេញចិត្តចំពោះការរីកចម្រើនដ៏ល្អប្រសើរ ក្នុងកិច្ចសហប្រតិបត្តិការលើផ្នែកសេដ្ឋកិច្ច ការផ្លាស់ប្តូរពាណិជ្ជកម្ម វិនិយោគទុន ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ ពិសេសក្នុងក្របខ័ណ្ឌ «**ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ**» ។

ឯកឧត្តម LIU GUANGYUAN បានពាំនាំនូវការសួរសុខទុក្ខរបស់ឯកឧត្តម WANG YI រដ្ឋមន្ត្រីក្រសួងការបរទេសចិន ជូនចំពោះ**ឯកឧត្តមទេសរដ្ឋមន្ត្រី** ហើយបានយល់ស្របចំពោះការវាយតម្លៃរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** ចំពោះការរីកចម្រើនដ៏ល្អប្រសើរនៃទំនាក់ទំនងមិត្តភាព និងកិច្ច

សហប្រតិបត្តិការ លើគ្រប់វិស័យរវាងប្រទេសទាំងពីរ និងបានវាយតំលៃខ្ពស់ចំពោះការរួមចំណែកដោយផ្ទាល់របស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏ដូចជារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ។

ឯកឧត្តមប្រធានគណៈប្រតិភូ បានជំរាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីគោលបំណងនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ មកកាន់កម្ពុជានៅពេលនេះ គឺដើម្បីធ្វើការជួបពិគ្រោះជាមួយភាគីកម្ពុជា ពាក់ព័ន្ធទៅនឹងការពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យសន្តិសុខ ហើយនិងការប្រឆាំងនឹងភេរវកម្ម និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេត ដែលស្របទៅតាមការព្រមព្រៀងគ្នារវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។

ឯកឧត្តម LIU GUANGYUAN ក៏បានជំរាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី ដោយគ្រួសៗអំពីលទ្ធផលផ្លែផ្កានៃការជួបពិគ្រោះពិភាក្សាផ្លាស់ប្តូរនូវព័ត៌មាននិងបទពិសោធន៍គ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ ការប្រឆាំងនឹងភេរវកម្ម និងការទប់ស្កាត់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេតរវាងក្រុមការងាររបស់ភាគីចិន ជាមួយនឹងក្រុមការងារអន្តរក្រសួងរបស់កម្ពុជាកាលពីព្រឹកមិញនេះ ហើយនិងការព្រមព្រៀងរបស់ភាគីទាំងពីរ ក្នុងការបង្កើតឡើងនូវយន្តការមួយសម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យដ៏សំខាន់នេះ និងបានស្នើសុំការគាំទ្ររបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក្នុងដំណើរការបង្កើតយន្តការនេះ។

ឯកឧត្តមប្រធានគណៈប្រតិភូ បានជំរាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការស្នើអញ្ជើញរបស់ភាគីចិន ចំពោះក្រុមការងារអន្តរក្រសួងរបស់កម្ពុជា ទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ក្នុងឆ្នាំ ២០១៧ ដើម្បីបន្តការពិភាក្សា ពីកិច្ចសហប្រតិបត្តិការលើការងារនេះ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងការពេញចិត្តចំពោះលទ្ធផលនៃការពិភាក្សារវាងក្រុមការងាររបស់ប្រទេសទាំងពីរ ហើយបានសម្តែងនូវការគាំទ្រចំពោះការព្រមព្រៀងក្នុងការបង្កើតអោយមានជាយន្តការសំរាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងទស្សនកិច្ចនៅប្រទេសចិនរបស់ក្រុមការងារកម្ពុជា នៅឆ្នាំក្រោយ ដើម្បីបន្តកិច្ចពិភាក្សាបន្តទៀត ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និង ឯកឧត្តមអគ្គនាយក LIU GUANGYUAN បានស្របទស្សនៈគ្នាលើភាពចាំបាច់ត្រូវបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ លើវិស័យសន្តិសុខ ការប្រឆាំងភេរវកម្ម និងការទប់ស្កាត់ឧក្រិដ្ឋតាមប្រព័ន្ធអ៊ីនធឺណេត ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៦